ព្រះរាជាណាចក្រកម្ពុជា

ស្ថានទូតព្រះរាជាណាចក្រកម្ពុជា
ប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍

លេខ ៦៧២ /១៧/សកប៤

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

យោងសេចក្តីជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧ ស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សូមជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនពលករទាំងអស់ជ្រាបថា គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ នឹងបើកយុទ្ធនាការបញ្ជាក់អត្តសញ្ញាណជូនបងប្អូនពលករកម្ពុជា ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស (OCWC) ចាប់ពី**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧** តទៅ ដែលមានព័ត៌មានដូចខាងក្រោម៖

## ក. ទីកន្លែង ថ្ងៃម៉ោងធ្វើការ និងតម្លៃសេវា សម្រាប់ការបញ្ជាក់អត្តសញ្ញាណ

### ក-១. ទីកន្លែង

១-ការិយាល័យទីក្រុងបាងកក៖ អាសយដ្ឋាន អ៊ីមផើរៀល វើល ឡាតប្រាវ (Imperial World Ladphrao) ជាន់ទី៤, លេខ២៥២៩, ច្រក៨១-៨៣, ផ្លូវឡាត់ប្រាវ, សង្កាត់ចៅឃុនស៊ីង, ខណ្ឌវ៉ាងថងឡាង ទីក្រុងបាងកក ១០៣១០

២-ការិយាល័យខេត្តរ៉ាក់យ៉ង៖ អាសយដ្ឋាន ផ្សារអូថប់ម៉ាយ៉ង (OTOP MA YONG) -២០១ ភូមិ៧, ឃុំម៉ាខាមឃូ, ស្រុកនិឃុំផាត់តាណា, ខេត្តរ៉ាក់យ៉ង ២១១៨០

៣-ការិយាល័យខេត្តសុងក្លា៖ អាសយដ្ឋាន ផ្សារហ្វុកទៀន(Fuk Thian), ៩៩ភូមិ៣, ឃុំខ្លងហែរ, ស្រុកហាត់យៃ, ខេត្តសុងក្លា

### ក-២. ថ្ងៃម៉ោងធ្វើការ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសៅរ៍

- បាងកក ៖ ព្រឹកម៉ោង ១០:០០ ដល់ ៦:៣០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៥:០០ ល្ងាច
- ខេត្តរ៉ាក់យ៉ង ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច
- ខេត្តសុងក្លា ៖ ព្រឹកម៉ោង ៨:៣០ ដល់ ៥:០០ ល្ងាច
  ពលករត្រូវមកដល់មុនម៉ោង ៣:៣០ ល្ងាច

### ក-៣. តម្លៃសេវា

តម្លៃសេវាផ្លូវការក្នុងការធ្វើ និងបើកផ្តល់សំណុំឯកសារក្នុងថ្ងៃតែមួយដែលភាគីថៃ និងកម្ពុជាបានឯកភាពគ្នា គឺ **២ ៣៥០**(ពីរពាន់បីរយហាសិប)បាត។

ខ. ឯកសារតម្រូវសម្រាប់ពលករមកស្នើសុំធ្វើលិខិតធ្វើដំណើរ និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស

១-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬសំបុត្រកំណើត ច្បាប់ដើម និងច្បាប់ថតចម្លងចំនួន ២ច្បាប់

២-ប័ណ្ណមិនមែនសញ្ជាតិថៃ (ប័ណ្ណស៊ីជម្ពូ) ឬលិខិតបញ្ជាក់ទំនាក់ទំនងរវាងនិយោជក និងពលករ ដែលចេញដោយក្រសួងការងារថៃ ឬមន្ទីរការងារថៃច្បាប់ដើម និងច្បាប់ថតចម្លងចំនួន ២ច្បាប់

៣-ប័ណ្ណអនុញ្ញាតការងារផ្នែកនេសាទ (សម្រាប់ពលករផ្នែកនេសាទ)

៤-ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់និយោជក

៥-ពលករត្រូវមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

គ. អ្នកក្នុងបន្ទុករបស់ពលករអាយុក្រោម ១៥ឆ្នាំមិនយកកម្រៃសេវា

១-ត្រូវនាំកូន ឬអ្នកក្នុងបន្ទុកមកដោយផ្ទាល់ និងថតរូបដោយផ្ទាល់

២-សំបុត្រកំណើតកូន ឬសំបុត្រពេទ្យ។

ក្នុងករណីបងប្អូនពលករដែលមានចម្ងល់ពាក់ព័ន្ធនឹងបញ្ហាបញ្ជាក់អត្តសញ្ញាណនេះ សូមទាក់ទងមកទូរស័ព្ទមន្ត្រីស្ថានទូតកម្ពុជានៅទីក្រុងបាងកក លេខ **០៨២ ៤២២ ០០១១/ ០៨២ ៤២២ ០០៤៤/ ០២ ៩៥៧ ៥៨៥២/ ០៩២ ៨០៥ ០៥៦១ /០៩៤ ០៩២ ៥៩០៥ /០៨៦ ៧៩៩ ៩៩៥៧ /០៦៤ ៧៥៥ ៧៤០១។**

អាស្រ័យន័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនពលករដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃជ្រាបជាព័ត៌មាន និងអនុវត្តទៅតាមខ្លឹមសារខាងលើនេះ។

ទីក្រុងបាងកក ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៧